**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យ លេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ភាពសក្តិសិទ្ធិ តម្លាភាព និងគណនេយ្យភាពនៃការបំពេញបេសកកម្ម

នៅក្នុងប្រទេស និងក្រៅប្រទេសរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះ៖

- សមាជិករាជរដ្ឋាភិបាល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ
- សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់
- ទីប្រឹក្សា ជំនួយការ
- មន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈនិង
- ជំនួយការហិរញ្ញវត្ថុនៃរដ្ឋបាលឃុំ សង្កាត់ ។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចខាងក្រោម៖

- បេសកកម្ម សំដៅដល់ការធ្វើដំណើរបំពេញភារកិច្ចជាក់លាក់ ជាប្រយោជន៍សាធារណៈ របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យា នៅក្នុងប្រទេសនិងក្រៅប្រទេស ក្នុងក្របខណ្ឌនៃមុខងាររបស់ក្រសួង ស្ថាប័ននីមួយៗនៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- ចំពោះរដ្ឋបាលកណ្តាល បេសកកម្មនៅក្នុងប្រទេស សំដៅដល់ការធ្វើបម្លាស់ទីចេញពីក្នុងរង្វង់ដែនដីនៃរាជធានី ។ ចំពោះករណីចាំបាច់ជាពិសេស ការធ្វើបម្លាស់ទីក្នុងរង្វង់រាជធានី អាចចាត់ទុកជាការបំពេញបេសកកម្ម ដោយត្រូវមានការឯកភាពជាគោលការណ៍ជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ចំពោះមន្ទីរជំនាញរាជធានី ខេត្ត បេសកកម្មនៅក្នុងប្រទេស សំដៅដល់ការធ្វើបម្លាស់ទីចេញពីក្នុងរង្វង់ដែនដីនៃរាជធានី ក្រុង ស្រុក ដែលសាមីខ្លួនបំពេញមុខងារជាប្រក្រតី ។ ចំពោះករណីចាំបាច់ជាពិសេស ការធ្វើបម្លាស់ទីក្នុងរង្វង់ដែនដីរាជធានី ក្រុង ស្រុក អាចចាត់ទុកជាការបំពេញបេសកកម្ម ដោយត្រូវមានការឯកភាពជាគោលការណ៍ជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ បេសកកម្មនៅក្នុងប្រទេស សំដៅដល់ការធ្វើបម្លាស់ទីចេញពីក្នុងរង្វង់ដែនដីនៃរាជធានី ឬរង្វង់ដែនដីនៃឃុំ សង្កាត់ នៃក្រុង ស្រុក ដែលសាមីខ្លួនបំពេញមុខងារជាប្រក្រតី ។



៤

**មាត្រា៤.-**

ការធ្វើដំណើរបេសកកម្មនៅក្នុងប្រទេស និងក្រៅប្រទេស មិនអនុញ្ញាតឱ្យរាប់បញ្ចូលការធ្វើដំណើរជាប្រចាំ ក៏ដូចជាការធ្វើដំណើរផ្ទាល់ខ្លួនទេ ។

ការបំពេញបេសកកម្មត្រូវគាំទ្រដោយមធ្យោបាយជាប្រាក់ដែលត្រូវបានកំណត់ថាជាប្រាក់បេសកកម្ម ។

ប្រាក់បេសកកម្មរួមមានប្រាក់ហោប៉ៅ ប្រាក់ហូបចុក ប្រាក់ស្នាក់នៅ សោហ៊ុយធ្វើដំណើរ ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍ និងប្រាក់ចំណាយផ្សេងៗ ដែលត្រូវកំណត់ និងផ្តល់ជូនទៅតាមប្រភេទបេសកកម្មនីមួយៗ ។ ប្រាក់ស្នាក់នៅត្រូវផ្តល់ជូនចំពោះបេសកកម្មដែលតម្រូវឱ្យមានការស្នាក់នៅពេលយប់ ។

ចំពោះបេសកកម្មដែលបំពេញដោយនាយករដ្ឋមន្ត្រី ទាំងនៅក្នុងប្រទេស ទាំងទៅក្រៅប្រទេស ប្រាក់បេសកកម្ម ត្រូវផ្តល់ជូនតាមសេចក្តីត្រូវការជាក់ស្តែង ។

**មាត្រា៥.-**

ឋានៈ និងបុព្វសិទ្ធិរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈគ្រប់លំដាប់ថ្នាក់ ទីប្រឹក្សា ឬជំនួយការដែលត្រូវបានតែងតាំងនៅក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិណាមួយ អាចធ្វើជាមូលដ្ឋានសម្រាប់កំណត់ប្រាក់បេសកកម្ម តែក្នុងករណីដែលសាមីខ្លួនបំពេញបេសកកម្មក្នុងក្របខណ្ឌការងាររបស់សាមីក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនោះផ្ទាល់ប៉ុណ្ណោះ។

ឋានៈ និងបុព្វសិទ្ធិ ដែលត្រូវបានតែងតាំងបន្ថែមលើឋានៈ និងបុព្វសិទ្ធ ដែលមានក្នុងរចនាសម្ព័ន្ធក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលខ្លួនកំពុងបំពេញការងារជាប្រក្រតី មិនអាចធ្វើជាមូលដ្ឋានសម្រាប់កំណត់ប្រាក់បេសកកម្មឡើយ ។

## ជំពូកទី២
## ប្រាក់បេសកកម្មនៅក្នុងប្រទេស

**មាត្រា៦.-**

ចំពោះបេសកកម្មដែលត្រូវបំពេញនៅក្នុងប្រទេស ប្រាក់បេសកកម្ម ត្រូវបានកំណត់ជា ៦ ប្រភេទ តាមមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម ÷

**ប្រភេទ ក:** ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងប្រធានស្ថាប័ន ឬអង្គភាព ដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ ខ១:** រដ្ឋលេខាធិការ និងអនុប្រធានស្ថាប័ន ឬអង្គភាព ដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ ខ២:** អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ គ:** អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋាន សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលរងរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ ឃ:** អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យថ្នាក់រដ្ឋបាលកណ្តាល និងថ្នាក់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលរងក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ ង:** មន្ត្រីរាជការសាធារណៈ មន្ត្រីជាប់កិច្ចសន្យា ទាំងនៅរដ្ឋបាលថ្នាក់ជាតិ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងជំនួយការហិរញ្ញវត្ថុនៃរដ្ឋបាល ឃុំ សង្កាត់ ។

**មាត្រា៧.-**

ប្រាក់បេសកកម្មនៅក្នុងប្រទេស ត្រូវបានកំណត់ដូចខាងក្រោម ÷

ឯកតា÷ រៀល

| ល.រ. | មុខតំណែង | ប្រាក់បេសកកម្មសម្រាប់១នាក់/១ថ្ងៃឬ១យប់ | | |
|---|---|---|---|---|
| | | ប្រាក់ហោប៉ៅ | ប្រាក់ហូបចុក | ប្រាក់ស្នាក់នៅ |
| ១ | ប្រភេទ ក | ៤០ ០០០ | ១២០ ០០០ | ២៤០ ០០០ |
| ២ | ប្រភេទ ខ១ | ៣៥ ០០០ | ៩០ ០០០ | ១៦០ ០០០ |
| ៣ | ប្រភេទ ខ២ | ៣០ ០០០ | ៨០ ០០០ | ១២០ ០០០ |
| ៤ | ប្រភេទ គ | ២៤ ០០០ | ៧០ ០០០ | ១០០ ០០០ |
| ៥ | ប្រភេទ ឃ | ២០ ០០០ | ៦០ ០០០ | ៨០ ០០០ |
| ៦ | ប្រភេទ ង | ១៦ ០០០ | ៦០ ០០០ | ៨០ ០០០ |

**មាត្រា៨.-**

ចំពោះកិច្ចប្រជុំកម្រិតអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុករៀបចំជាម្ចាស់ផ្ទះ ប្រាក់បេសកកម្មត្រូវគិតបញ្ចូលទៅក្នុងគម្រោងចំណាយនៃកម្មវិធីប្រជុំកម្រិតអន្តរជាតិ តាមការកំណត់ដូចខាងក្រោម ÷

ឯកតា÷ រៀល

| ល.រ. | មុខតំណែង | ប្រាក់បេសកកម្មសម្រាប់១នាក់/១ថ្ងៃឬ១យប់ | | |
|---|---|---|---|---|
| | | ប្រាក់ហោប៉ៅ | ប្រាក់ហូបចុក | ប្រាក់ស្នាក់នៅ |
| ១ | ប្រភេទ ក | ៧០ ០០០ | ១២០ ០០០ | ៤០០ ០០០ |
| ២ | ប្រភេទ ខ១ | ៦០ ០០០ | ៩០ ០០០ | ៣៥០ ០០០ |
| ៣ | ប្រភេទ ខ២ | ៥០ ០០០ | ៨០ ០០០ | ៣០០ ០០០ |
| ៤ | ប្រភេទ គ | ៤០ ០០០ | ៧០ ០០០ | ២០០ ០០០ |
| ៥ | ប្រភេទ ឃ | ៣០ ០០០ | ៦០ ០០០ | ១៦០ ០០០ |
| ៦ | ប្រភេទ ង | ២០ ០០០ | ៦០ ០០០ | ១២០ ០០០ |

**មាត្រា៩.-**

សោហ៊ុយធ្វើដំណើរសម្រាប់បេសកកម្មនៅក្នុងប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា១០.-**

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ ត្រូវធ្វើវិចារណកម្មលើចំណាយប្រាក់បេសកកម្មដោយកាត់បន្ថយជាអតិបរមានូវចំនួនបេសកកម្មមិនចាំបាច់ ឬកម្រិតចំនួនមន្ត្រីបំពេញបេសកកម្មពីថ្នាក់ជាតិដោយប្រើប្រាស់មន្ត្រីជំនាញពាក់ព័ន្ធនៅរដ្ឋបាលថ្នាក់ក្រោមជាតិជំនួសវិញ ក្នុងករណីមិនមានការហាមឃាត់ដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី៣

## ប្រាក់បេសកកម្មនៅក្រៅប្រទេស

**មាត្រា១១.-**

ចំពោះបេសកកម្មដែលត្រូវបំពេញនៅក្រៅប្រទេសដោយគណៈប្រតិភូដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រាក់បេសកកម្មត្រូវបានកំណត់ជា ៦ ប្រភេទ តាមមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម ÷



ឝ

**ប្រភេទ ក១:** -ឧបនាយករដ្ឋមន្ត្រី

-ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងប្រធានស្ថាប័ន ឬអង្គភាព ដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ដែលបំពេញបេសកកម្មក្នុងឋានៈជាប្រធានគណៈប្រតិភូ ។

**ប្រភេទ ក២:** -ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬអង្គភាព ដែលបំពេញបេសកកម្មក្នុងឋានៈជាសមាជិកគណៈប្រតិភូ

- រដ្ឋលេខាធិការ និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ ខ:** អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ គ:** អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង ប្រធាននាយកដ្ឋាន សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលរងរាជធានី ខេត្ត ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ ឃ:** អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ អនុប្រធានការិយាល័យថ្នាក់រដ្ឋបាលកណ្តាល និងថ្នាក់រដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អភិបាលរងក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ។

**ប្រភេទ ង:** មន្ត្រីរាជការសាធារណៈ មន្ត្រីជាប់កិច្ចសន្យា ទាំងនៅរដ្ឋបាលថ្នាក់ជាតិ ទាំងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងជំនួយការហិរញ្ញវត្ថុនៃរដ្ឋបាល ឃុំ សង្កាត់ ។

**មាត្រា១២.-**

ប្រាក់បេសកកម្មទៅក្រៅប្រទេសត្រូវបានកំណត់ទៅតាមក្រុមប្រទេស ដូចខាងក្រោម÷

**ក្រុមទី១:** បណ្តាប្រទេសអាស៊ីអាគ្នេយ៍ (លើកលែងតែប្រទេសព្រុយណេ និងប្រទេសសិង្ហបុរី) និងអាស៊ីខាងត្បូង។

**ក្រុមទី២:** បណ្តាប្រទេសនៅតំបន់អាស៊ីខាងកើត អាស៊ីកណ្តាល អាស៊ីខាងលិច អឺរ៉ុបខាងកើត អឺរ៉ុបខាងត្បូង អាមេរិកកណ្តាល និងការ៉ាបៀន អាមេរិកខាងត្បូង អាហ្វ្រិក អូសេអានី ព្រមទាំងប្រទេសព្រុយណេ និងសិង្ហបុរី ។

**ក្រុមទី៣:** បណ្តាប្រទេសនៅតំបន់អឺរ៉ុបខាងលិច អឺរ៉ុបខាងជើង អាមេរិកខាងជើង ព្រមទាំងប្រទេសកូរ៉េខាងត្បូង ជប៉ុន រុស្ស៊ី អ៊ីតាលី អេស្ប៉ាញ ព័រទុយហ្កាល់ អាហ្វ្រិកខាងត្បូង អូស្រ្តាលី និងនូវែលសេឡង់ ។

**មាត្រា១៣.-**

ប្រាក់បេសកកម្មទៅក្រៅប្រទេសត្រូវកំណត់ដូចខាងក្រោម÷

ឯកតា÷ ដុល្លារអាមេរិក

| មុខតំណែង | ប្រាក់បេសកកម្មសម្រាប់១នាក់/១ថ្ងៃឬយប់ | | | | | | |
|---|---|---|---|---|---|---|---|
| | ប្រាក់ហោប៉ៅ | ប្រាក់ហូបចុក | | | ប្រាក់ស្នាក់នៅ | | |
| | | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ | ក្រុមទី១ | ក្រុមទី២ | ក្រុមទី៣ |
| ប្រភេទ ក១ | ៥០ | ៩០ | ១០០ | ១២០ | ៣០០ | ៤០០ | ៥០០ |
| ប្រភេទ ក២ | ៥០ | ៩០ | ១០០ | ១២០ | ៣០០ | ៣៥០ | ៤០០ |
| ប្រភេទ ខ | ៤០ | ៨០ | ៩០ | ១០០ | ២៥០ | ៣០០ | ៣៥០ |
| ប្រភេទ គ | ៣០ | ៧០ | ៨០ | ៩០ | ២០០ | ២៥០ | ៣០០ |
| ប្រភេទ ឃ | ២៥ | ៦០ | ៧០ | ៨០ | ១៧០ | ២២០ | ២៧០ |
| ប្រភេទ ង | ២០ | ៦០ | ៧០ | ៨០ | ១៥០ | ២០០ | ២៥០ |

**មាត្រា១៤.-**

សោហ៊ុយធ្វើដំណើរត្រូវផ្តល់ជូនតាមចំនួនទឹកប្រាក់កត់ត្រាក្នុងវិក្កយបត្រ ដោយគិតរួមបញ្ចូលទាំងថ្លៃបង់ពន្ធព្រលានយន្តហោះផង ។ សំបុត្រយន្តហោះត្រូវផ្តល់ជូនតាមឋានៈដូចខាងក្រោម ÷

១. សំបុត្រយន្តហោះថ្នាក់ទី១ (First Class) សម្រាប់ឧបនាយករដ្ឋមន្ត្រី ឬអ្នកដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ។

២. សំបុត្រយន្តហោះថ្នាក់ជំនួញ (Business Class)

ក. សម្រាប់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬសមាជិកស្ថាប័ន ឬអង្គភាពនានាដែលមានឋានៈ និងបុព្វសិទ្ធិ ស្មើមុខតំណែងនេះ ។

ខ. សម្រាប់អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ដើម្បីចូលរួមប្រជុំផ្លូវការ ឬកិច្ចចរចាទ្វេភាគី ឬពហុភាគី តាមការប្រគល់សិទ្ធិរបស់ប្រធានស្ថាប័ន និងដែលត្រូវធ្វើដំណើរលើសពីបួនម៉ោង។ ដោយឡែកចំពោះការធ្វើដំណើរផ្សេងពីនេះដូចជាការ

ចូលរួមសន្និសីទអន្តរជាតិ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ឬទស្សនកិច្ចសិក្សាជាដើម មិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់សំបុត្រយន្តហោះថ្នាក់ជំនួញទេ ។

៣. សំបុត្រយន្តហោះថ្នាក់សន្សំសំចៃ (Economy Class)

ក. សម្រាប់អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬអ្នកដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះ ដែលត្រូវធ្វើដំណើរចាប់ពីបួនម៉ោងចុះ ។

ខ. សម្រាប់អគ្គលេខាធិការរង អគ្គនាយករង អគ្គាធិការរង សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ឬមន្ត្រីរាជការសាធារណៈនៃក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះចុះក្រោម ។

**មាត្រា១៥.-**

ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសន្សំសំចៃលើចំណាយថវិកាចំពោះប្រាក់បេសកកម្មនៅក្រៅប្រទេស តាមវិធីដូចខាងក្រោម ÷

- ការប្រើប្រាស់ជើងហោះហើរត្រង់ដែលមានការសន្សំសំចៃបំផុតតាមដែលអាចធ្វើទៅបាន
- ការកាត់បន្ថយសមាជិកឱ្យនៅចំនួនតិចបំផុត តាមដែលអាចធ្វើទៅបាន
- ការស្នើសុំគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដើម្បីឱ្យស្ថានទូតកម្ពុជាប្រចាំប្រទេសនោះចូលរួមជំនួស។

**មាត្រា១៦.-**

ប្រាក់ចំណាយលើវត្ថុអនុស្សាវរីយ៍ត្រូវផ្តល់ជូនចំពោះបេសកកម្មដែលដឹកនាំដោយអគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ឬមន្ត្រីរាជការសាធារណៈដែលមានឋានៈ និងបុព្វសិទ្ធិស្មើមុខតំណែងនេះឡើងទៅ ។ គោលរបបសម្រាប់ផ្តល់វត្ថុអនុស្សាវរីយ៍ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា១៧.-**

ប្រាក់ចំណាយផ្សេងៗត្រូវផ្តល់ជូនក្នុងកម្រិតមួយសមស្របនិងតាមករណីចាំបាច់ ដោយផ្អែកលើគម្រោងរបស់ក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្នើសុំចំណាយ ។

**មាត្រា១៨.-**

សមាសភាពគណៈប្រតិភូដែលមានសហព័ទ្ធអមដំណើរក្នុងការបំពេញបេសកកម្ម ត្រូវទទួលបន្ទុកផ្ទាល់ខ្លួនលើការចំណាយទាំងអស់សម្រាប់សហព័ទ្ធរបស់ខ្លួន ។

ចំពោះឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬ

ប្រធានអង្គភាពនានាដែលមានឋានៈ និងបុព្វសិទ្ធិស្មើ ដែលមានសហព័ទ្ធអមដំណើរតាមការអនុញ្ញាតពីនាយករដ្ឋមន្ត្រី ប្រាក់ចំណាយសម្រាប់សហព័ទ្ធ ត្រូវផ្តល់ជូនតែសោហ៊ុយធ្វើដំណើរ និងប្រាក់ហូបចុកប៉ុណ្ណោះ ។

## ជំពូកទី៤
## នីតិវិធីអនុវត្ត

**មាត្រា១៩.-**

ចំពោះបេសកកម្មនៅក្នុងប្រទេស ប្រាក់បេសកកម្មត្រូវផ្តល់ជូនតាមវិធាននិងនីតិវិធី ដូចខាងក្រោម÷

- ប្រាក់បេសកកម្មត្រូវកម្រិតខ្ពស់បំផុតត្រឹម ១០ (ដប់) ថ្ងៃក្នុងមួយខែ ។
- ក្នុងករណីមានបេសកកម្មលើសពីចំនួនថ្ងៃកំណត់ខាងលើក្រសួង ស្ថាប័ន អង្គភាព រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្នើសុំទិដ្ឋាការធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។
- ប្រាក់បេសកកម្មត្រូវទូទាត់ជាប្រាក់រៀល ។

**មាត្រា២០.-**

ចំពោះបេសកកម្មទៅក្រៅប្រទេស ប្រាក់បេសកកម្មត្រូវផ្តល់ជូនតាមវិធាននិងនីតិវិធី ដូចខាងក្រោម÷

- អាណាប័កត្រូវស្នើសុំទិដ្ឋាការធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់ឯកសារពាក់ព័ន្ធគ្រប់គ្រាន់ ។ ចំពោះបេសកកម្មដែលមិនមានគោលការណ៍/ធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬគោលការណ៍ជាមុនពីរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មាននិត្យានុកូលភាពក្នុងការបដិសេធការទូទាត់ចំណាយប្រាក់បេសកកម្មនោះ ហើយអាណាប័កត្រូវទទួលខុសត្រូវតាមបទប្បញ្ញត្តិជាធរមាន ។
- ប្រាក់បេសកកម្មដែលបានទទួលទិដ្ឋាការធានាចំណាយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួចហើយ អាណាប័កអាចបោះផ្សាយអាណត្តិបើកប្រាក់ជារបបកំណត់សម្រាប់ផ្តល់ជូនតែម្តង ប៉ុន្តែត្រូវបំពេញឯកសារទូទាត់តាមក្រោយតាមការជាក់ស្តែង ។
- មុខចំណាយទាំងឡាយណាដែលត្រូវបានទទួលរ៉ាប់រងពីភាគីអញ្ជើញ មិនត្រូវបានផ្តល់ជូនឡើយនៅក្នុងប្រាក់បេសកកម្ម។ ក្នុងករណីដែលរាល់មុខចំណាយទាំងអស់ត្រូវបានធានាជាបន្ទុកទាំងស្រុងរបស់ភាគីអញ្ជើញ មានតែប្រាក់ហោប៉ៅប៉ុណ្ណោះដែលត្រូវផ្តល់ជូនជាប្រាក់បេសកកម្ម និងមានកម្រិតមិនលើសពី ១០ (ដប់)ថ្ងៃ ។
- ប្រាក់បេសកកម្មត្រូវកម្រិតខ្ពស់បំផុតត្រឹម ១០ (ដប់) ថ្ងៃក្នុងមួយខែ ។
- ក្នុងករណីមានបេសកកម្មលើសពីចំនួនថ្ងៃកំណត់ខាងលើក្រសួង ស្ថាប័ន អង្គភាពរដ្ឋបាលថ្នាក់ជាតិ

និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្នើសុំទិដ្ឋាការធានាចំណាយជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ក្នុងករណីមានការពន្យារពេលបំពេញបេសកកម្មដោយមូលហេតុសត្យានុម័ត ប្រាក់បេសកកម្មអាចផ្តល់ជូនបន្ថែមបាន លុះត្រាតែមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ អាណាប័កត្រូវទទួលខុសត្រូវលើភាពត្រឹមត្រូវនៃលិខិតយុត្តិការចំណាយរបស់គណៈប្រតិភូ រួមទាំងរបាយការណ៍សម្រាប់ជាមូលដ្ឋាននៃការទូទាត់បន្ថែមនេះ។

**មាត្រា២១.-**

រាល់បេសកកម្មនៅក្នុងនិងក្រៅប្រទេសដែលបានអនុវត្តនៅក្នុងត្រីមាសទី ៤ នៃឆ្នាំមុន មិនទាន់ទូទាត់ ត្រូវបានអនុញ្ញាតឱ្យទូទាត់ក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹមត្រីមាសទីមួយនៃឆ្នាំបន្ទាប់ ដោយអនុវត្តនីតិវិធីទូទាត់ត្រង់ និងប្រើឥណទានថវិកានៅឆ្នាំបន្ទាប់ ។ ហួសកាលកំណត់នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមាននិត្យានុកូលភាពគ្រប់គ្រាន់ក្នុងការបដិសេធការទូទាត់ប្រាក់បេសកកម្ម លើកលែងតែមានការពន្យល់ច្បាស់លាស់ពីមូលហេតុនៃការយឺតយ៉ាវ ។

រាល់បេសកកម្មនៅក្នុងនិងក្រៅប្រទេសដែលបានអនុវត្តនៅក្នុងបីត្រីមាសដំបូងនៃឆ្នាំមុន និងបណ្តាឆ្នាំកន្លងទៅ មិនត្រូវបានអនុញ្ញាតឱ្យទូទាត់នៅឆ្នាំបន្ទាប់ឡើយ ។

**មាត្រា២២.-**

ក្នុងករណីការបំពេញបេសកកម្មដោយពុំមានទិដ្ឋាការធានាចំណាយជាមុន ពីអ្នកត្រួតពិនិត្យហិរញ្ញវត្ថុក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិត្រួតពិនិត្យតាមគ្រប់រូបភាព និងសម្រេចដូចតទៅ ÷

- បដិសេធការទូទាត់ប្រាក់បេសកកម្ម កាលបើពិនិត្យឃើញថា មិនអនុលោមតាមវិធាន និងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។
- អនុវត្តការទូទាត់ប្រាក់បេសកកម្ម កាលបើពិនិត្យឃើញថា មានភាពត្រឹមត្រូវតាមវិធាន និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។ ក្នុងករណីនេះ ប្រាក់បេសកកម្មត្រូវគិតជាប្រាក់រៀល ។

**មាត្រា២៣.-**

វិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស ត្រូវកំណត់លម្អិតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**មាត្រា២៤.-**

មន្ត្រីរាជការសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈ រួមទាំងមន្ត្រីជាប់កិច្ចសន្យា ត្រូវទទួលទណ្ឌកម្ម

រដ្ឋបាលនិងសំណងរដ្ឋប្បវេណី តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬ សមគំនិតក្នុងការប្រព្រឹត្ត ដូចខាងក្រោម ÷

- ការក្លែងបន្លំលិខិតយុត្តិការចំណាយ និងលិខិតស្នាមផ្សេងៗ ក្នុងគោលបំណងទទួលបានប្រាក់បេសកកម្ម ដែលខ្លួនពុំមានសិទ្ធិទទួលតាមការកំណត់នៃអនុក្រឹត្យនេះ
- ការបង្វែរ ឬកេងប្រវ័ញ្ចប្រាក់បេសកកម្ម ដើម្បីយកទៅប្រើប្រាស់ក្រៅពីការបំពេញបេសកកម្ម
- ការបង្កើនរយៈពេលបំពេញបេសកកម្ម និង/ឬ ចំនួនមន្ត្រីចុះធ្វើបេសកកម្ម ដែលខុសពីបេសកកម្មដែលបានអនុវត្តជាក់ស្តែង
- ការបង្កើតបេសកកម្មដោយក្លែងបន្លំក្នុងគោលបំណងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម
- ការទទួលបានប្រាក់បេសកកម្មតែមិនបានផ្តល់ជូនសាមីមន្ត្រីរាជការសាធារណៈដែលត្រូវបំពេញបេសកកម្ម
- ការរារាំង ឬការព្យាយាមរារាំង ដល់ដំណើរការត្រួតពិនិត្យប្រក្រតីភាពនៃការអនុវត្តប្រាក់បេសកកម្ម ។

ទណ្ឌកម្មនេះមិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់ និងការផ្តន្ទាទោសព្រហ្មទណ្ឌ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា២៥.-**

អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមានជាអាទិ៍÷

- ការស្តីបន្ទោស
- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា២៦.-**

អនុក្រឹត្យនេះមានប្រសិទ្ធភាពអនុវត្តជំនួសអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេស សម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា២៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានគ្រប់អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃអង្គារ ៦ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ